**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី
លេខ: ២៧៣/០០៥/២០២៣ ជ.អ.ល.

**លេខ៖ ២០២៣/EGM/០១**

**ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៣**

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី** (**ជ.អ.ល.**) មានកិត្តិយសសូមជម្រាបជូនម្ចាស់ភាគហ៊ុនទាំងអស់របស់ ជ.អ.ល. ថា ក្រុមហ៊ុន **ជ.អ.ល.** នឹងធ្វើការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២៣។ គោលបំណងក្នុងការបើកកោះប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញនេះ គឺដោយសារតែក្រុមហ៊ុនមានតម្រូវការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូនក្រុមប្រឹក្សាភិបាលដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីក្នុងនាមជាភាគហ៊ុនិក។

របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញមានកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក៖ **ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០២៣**
២. កាលបរិច្ឆេទប្រារព្ធកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ៖ **ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ ព្រឹក**
៣. ទីកន្លែងនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ៖ សន្និសីទតាមរយៈប្រព័ន្ធអនឡាញ Zoom
៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរួមមាន៖

ក. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូន លោក Yap Maow Jun អភិបាលមិនប្រតិបត្តិរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីក្នុងនាមជាតំណាងភាគហ៊ុនិកសាធារណៈ។

ខ. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូន (i) ឧកញ៉ា កួយ ឡេសាន ប្រធានក្រុមប្រឹក្សាភិបាល និង (ii) លោក Dato' Yap Ting Chiat អគ្គនាយកប្រតិបត្តិ/អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីក្រោមចំនួន ២.០០០.០០០ ដុល្លារអាមេរិក ក្នុងនាមជាតំណាងក្រុមហ៊ុន និងតំណាងភាគហ៊ុនិកសាធារណៈ។

គ. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូនក្រុមប្រឹក្សាភិបាលទាំងអស់របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីច្រើនជាងចំនួន ២.០០០.០០០ ដុល្លារអាមេរិក ទៅដល់ ៥.០០០.០០០ ដុល្លារអាមេរិក ក្នុងនាមជាតំណាងក្រុមហ៊ុន និងតំណាងភាគហ៊ុនិកសាធារណៈ។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកនៅថ្ងៃទី **២២ ខែមិថុនា ឆ្នាំ ២០២៣** (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញតាមរយៈសារអេឡិចត្រូនិកពី**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ **ជ.អ.ល**) **ចាប់ពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៣។** បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាបញ្ជាក់អំពីការចូលរួមទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈសារអេឡិចត្រូនិក ឬលេខទំនាក់ទំនង ដូចបានបញ្ជាក់ជូនខាងក្រោម **ចាប់ពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៣។**

ក្នុងករណីភាគហ៊ុនិកណាមួយដែលមិនអាចចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់ ភាគហ៊ុនិកអាចប្រគល់សិទ្ធិជូនបុគ្គលណាមួយដែលជាតំណាងដើម្បីចូលរួមកិច្ចប្រជុំ។ ទម្រង់នៃលិខិតប្រគល់សិទ្ធិនឹងត្រូវបានផ្ញើទៅកាន់ភាគហ៊ុនិករួមជាមួយនឹងលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ។ ភាគហ៊ុនិក ឬអ្នកតំណាងត្រូវ**ផ្តល់ជូនលិខិតប្រគល់សិទ្ធិនេះ**តាមរយៈសារអេឡិចត្រូនិចមកកាន់ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ របស់អេស៊ីលីដា **ចាប់ពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៣ ដល់ថ្ងៃថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៣។**

ភាគហ៊ុនិកដែលមិនបានបញ្ជាក់ពីការចូលរួមកិច្ចប្រជុំ ឬមិនបានផ្តល់ជូនលិខិតប្រគល់សិទ្ធិនេះដល់ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ **របស់ធនាគារ អេស៊ីលីដា** តាមកាលកំណត់ខាងលើ នឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** និង **ជេអេស លែន ភីអិលស៊ី** តាមរយៈអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

**១. ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាស័យដ្ឋាន: ជាន់ទី៥ ផ្ទះលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥) ២៣ ៩៩៨ ៧៧៧
- ទូរសារ: (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ: (៨៥៥) ១៥ ៩០០ ៥៣៨ (Ext: ០៥០១៨)<br>(៨៥៥) ១៥ ៨០០ ៦៦៣<br>(៨៥៥) ៦១ ២៨៧ ៧៦៦
- សារអេឡិចត្រូនិក: huot.sophy@acleda.com.kh

**២. ជេអេស លែន ភីអិលស៊ី**

- អាស័យដ្ឋានៈ  អគារអ៊ីឡេសេកោះពេជ្រ, ផ្លូវ កោះពេជ្រ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ
- ទូរសព្ទដៃៈ  ០១០ ៨៨៦ ៦៩៩
- សារអេឡិចត្រូនិកៈ info@jslandplc.com

**ជ.គណៈកម្មាធិការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ**

**ប្រធាន**

**ភួយ ឡេសាន**

**ចម្លងជូន៖**

- និយ័តករមូលបត្រកម្ពុជា (**ន.ម.ក**)
- ផ្សារមូលបត្រកម្ពុជា (**ផ.ម.ក**)
- សមាជិកក្រុមប្រឹក្សាភិបាលរបស់ **ជ.អ.ល**
- សវនករឯករាជ្យរបស់ **ជ.អ.ល**
  ក្រុមហ៊ុន **ហ្វ្រែន ថនតុន**